# ធនាគារ អេស៊ីលីដា ភីអិលស៊ី

# ACLEDA Bank Plc.

## សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី (ធ.អ.ក)** សូមជម្រាបជូនវិនិយោគិន និងសាធារណជនទទួលជ្រាបថា៖ មហាសន្និបាតភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៤:៣០នាទី នៅការិយាល័យកណ្តាលធនាគារ មានកូរ៉ុមចំនួន៩៩,០៥% និងមានភាគហ៊ុនិកចូលរួមចំនួន៩១នាក់ ស្មើនឹង ៤២៩.០២៩.៥០១ ភាគហ៊ុន។

អង្គប្រជុំបានពិនិត្យ ពិភាក្សានិងបានអនុម័តនូវចំណុចដូចខាងក្រោម៖

១- អនុម័តលើការផ្លាស់ប្តូរស្លាកសញ្ញារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីកែលម្អនូវរូបរាងស្លាកសញ្ញា និងអត្តសញ្ញាណរបស់ធនាគារ។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

២- អនុម័តលើការវិនិយោគរបស់ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ក្នុងទំហំទឹកប្រាក់ចំនួន **១០លានដុល្លារអាមេរិក** ដើម្បីទទួលបានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួន **៦.០៤៧.០៤៦ ភាគហ៊ុន** ស្មើនឹង **២៣,៣៩១០%** នៃភាគហ៊ុនសរុបរបស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រ ដោយសម្លេង ៩៩,៩៩ ភាគរយ ។*

៣- អនុម័តដកការវិនិយោគរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅស្ថាប័ន មីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

៤- អនុម័ត និងទទួលស្គាល់លោក Albertus Bruggink មកពីស្ថាប័ន ORIX Corporation ជាអភិបាលថ្មី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Ryoji Nishimura។ កាលបរិច្ឆេទទទួលស្គាល់នេះ មានប្រសិទ្ធភាពអនុវត្តនៅពេលទទួលបានការអនុម័តពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

៥- អនុម័ត និងការទទួលស្គាល់ការចូលនិវត្តន៍របស់ លោកស្រី Mirjam Janssen ជាអភិបាលដែលបានតែងតាំងដោយធនាគារ Triodos នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ ការចូលនិវត្តន៍នេះ នឹងមានប្រសិទ្ធភាពអនុវត្តនៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទទួលស្គាល់ជាផ្លូវការ ចំពោះបេក្ខភាពអភិបាល ដែលត្រូវបានតែងតាំងដោយក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

៦- អនុម័ត និងទទួលស្គាល់ លោក កាយ ឡូត ជាអភិបាលទីពីរ របស់ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ កាលបរិច្ឆេទទទួលស្គាល់នេះ នឹងមានប្រសិទ្ធភាពអនុវត្ត នៅពេលទទួលបានការអនុម័តពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

៧- អនុម័ត និងទទួលស្គាល់ លោក Hideomi Shigematsu មកពីស្ថាប័ន SMBC ជាតំណាងភាគហ៊ុនិកថ្មីនៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Yuichi Nishimura។ *ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។*

៨- អនុម័តការកែប្រែលក្ខន្តិកៈត្រង់មាត្រា ៥.២ មាត្រា ៦.១ មាត្រា ៨ ឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ និងបន្ថែមមាត្រា ៧.៩ និង ឧបសម្ព័ន្ធ ៣ "បញ្ជីឈ្មោះភាគហ៊ុនិកសាធារណៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី" នៃអនុស្សរណៈ និងលក្ខន្តិកៈ ធនាគារ អេស៊ីលីដា ភីអិលស៊ី។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។***

៩- អនុម័តជ្រើសរើសក្រុមហ៊ុន Grant Thornton ជាសវនករឯករាជ្យប្រចាំធនាគារ សម្រាប់២០២១។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រជាឯកច្ឆន្ទ។***

អង្គមហាសន្និបាត បានបិទបញ្ចប់នៅវេលាម៉ោង ១៦:២៣ នាទី នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៩កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

អេស៊ីលីដា
ACLEDA
ACLEDA Bank Plc.